# របាយការណ៍

## បូកសរុបលទ្ធផលការពិភាក្សាក្នុងសន្និបាតបូកសរុបសភាពការណ៍អនុវត្តការងារទេសចរណ៍ ឆ្នាំ២០១២-២០១៣ និងទិសដៅអនុវត្តបន្ត "ទេសចរណ៍កម្ពុជាឆ្ពោះទៅសមាហរណកម្មអាស៊ាន ឆ្នាំ២០១៥" និងអបអរសាទរទិវាជាតិទីក្រុងស្អាត ក្រោមប្រធានបទ "សកម្មភាពរបស់អ្នក ដើម្បីទីក្រុងស្អាត" ដោយ ឯកឧត្តម ថោង ខុន រដ្ឋមន្ត្រីក្រសួងទេសចរណ៍ នៅបុរីកោះពេជ្រ ថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០១៤

*សូមគោរព៖*

- *សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ជាទីគោរពដ៏ខ្ពង់ខ្ពស់បំផុត!*
- *ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី*
- *ឯកឧត្តម លោកជំទាវ អគ្គរាជទូត អគ្គរដ្ឋទូត ភ្ញៀវកិត្តិយសជាតិ និងអន្តរជាតិ និងអង្គសន្និបាត ជាទីគោរព និងជាទីមេត្រី!*

ថ្ងៃនេះ តាងនាមថ្នាក់ដឹកនាំ មន្ត្រីរាជការទាំងអស់នៃក្រសួងទេសចរណ៍ និងសមាជិក សមាជិកានៃអង្គសន្និបាតទាំងមូល និងខ្លួនខ្ញុំបាទផ្ទាល់ យើងខ្ញុំសូមសំដែងនូវសេចក្តីសោមនស្សរីករាយ ប្រកបដោយមោទនភាព និងកិត្តិយសដ៏ខ្ពង់ខ្ពស់បំផុត ដោយ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** បានឆ្លៀតឱកាសដ៏មមាញឹកក្នុងបេសកកម្មបំរើប្រទេសជាតិ និងប្រជាជន អញ្ជើញជាអធិបតីដ៏ខ្ពង់ខ្ពស់ក្នុងពិធីបិទសន្និបាតបូកសរុបសភាពការណ៍អនុវត្តការងារទេសចរណ៍ឆ្នាំ២០១២-២០១៣ និងទិសដៅអនុវត្តបន្ត **"ទេសចរណ៍កម្ពុជាឆ្ពោះទៅរកសមាហរណកម្មអាស៊ានឆ្នាំ២០១៥"** និងអបអរសាទរ**ទិវាជាតិទីក្រុងស្អាត** ក្រោមប្រធានបទ **"សកម្មភាពរបស់អ្នក ដើម្បីទីក្រុងស្អាត"**ដ៏មានសារៈសំខាន់នេះ។

ខ្ញុំបាទសូមថ្លែងអំណរគុណចំពោះ ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី ភ្ញៀវជាតិ និងអន្តរជាតិ ដែលបានអញ្ជើញចូលរួមក្នុងពិធីបិទសន្និបាតនេះ។

ខ្ញុំបាទមានកិត្តិយសដ៏ខ្ពង់ខ្ពស់ សូមគោរពរាយការណ៍ជូន **សម្តេចតេជោនាយករដ្ឋមន្ត្រី** មេត្តាជ្រាបថា សន្និបាតលើកនេះ មានការចូលរួមពីក្រសួង-ស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិ សមត្ថកិច្ចពាក់ព័ន្ធ សាកលវិទ្យាល័យ សាលាបណ្តុះបណ្តាលវិជ្ជាជីវៈ ផ្នែកឯកជនពាក់ព័ន្ធ យុវជន អង្គការក្រៅរដ្ឋាភិបាល អង្គការជាតិ-អន្តរជាតិ និងអង្គទូតនានា សរុបប្រមាណ **៨០០នាក់**។ អង្គសន្និបាតបានដំណើរការយ៉ាងសកម្មអស់រយៈ **០៥ពេល** ចាប់ពីព្រឹក**ថ្ងៃទី២៦ ដល់ថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០១៤** ។ **ឯកឧត្តម សុខ អាន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី** បានផ្តល់កិត្តិយសអញ្ជើញជាអធិបតីក្នុងពិធីបើកអង្គសន្និបាតនេះ។

អង្គសន្និបាតធ្វើការពិភាក្សាលើប្រធានបទមួយចំនួនដែលពាក់ព័ន្ធនឹងចំណុចគន្លឹះសំខាន់ៗ ដើម្បីឆ្លើយតបនឹងផែនការអភិវឌ្ឍន៍ទេសចរណ៍អាស៊ាន (ATSP) ឆ្នាំ២០១១-២០១៥ ដូចជា៖

**១.ការអភិវឌ្ឍផលិតផលទេសចរណ៍ និងការវិនិយោគទេសចរណ៍**

**២. ការសិក្សាទីផ្សារ និងផ្សព្វផ្សាយទេសចរណ៍**

**៣.ការពង្រឹងគុណភាពផលិតផលទេសចរណ៍**

**៤.ការអភិវឌ្ឍធនធានមនុស្សក្នុងវិស័យទេសចរណ៍**

**៥.ការជំរុញការតភ្ជាប់ (Connectivity) និង សម្រួលការធ្វើដំណើរដល់ទេសចរណ៍**

**៦. អភិបាលកិច្ចល្អនិងការពង្រឹងយន្តការទ្រទ្រង់ការអភិវឌ្ឍទេសចរណ៍កម្ពុជា**

**៧. ចលនាប្រលងប្រណាំងទីក្រុងស្អាត រមណីយដ្ឋានស្អាត សេវាល្អ**

ទន្ទឹមនឹងនេះ ដើម្បីចូលរួមអបអរសាទរ **"ទិវាជាតិទីក្រុងស្អាត"** លើកទី២ ថ្ងៃទី២៧ ខែកុម្ភៈ កាលពីព្រឹកមិញនេះ អង្គសន្និបាតបានស្ដាប់សារលិខិតរបស់**សម្ដេចតេជោនាយករដ្ឋមន្ត្រី និងជាប្រធានកិត្តិយសនៃគណៈកម្មាធិការជាតិវាយតម្លៃទីក្រុងស្អាត** ផ្ញើជូនជនរួមជាតិ ក្រោមប្រធានបទ **"សកម្មភាព របស់អ្នក ដើម្បីទីក្រុងស្អាត"**នាឱកាសទិវាជាតិទីក្រុងស្អាត **ហើយគ.ជ.វ.ទ** ក៏បានធ្វើការជម្រាបជូនពីលទ្ធផលដំណាក់កាលដំបូងនៃការវាយតម្លៃទីក្រុងស្អាត ជូនក្រុង-ខណ្ឌបេក្ខភាព ផងដែរ។

- *សម្ដេចតេជោនាយករដ្ឋមន្ត្រី ជាទីគោរពដ៏ខ្ពង់ខ្ពស់បំផុត!*
- *ឯកឧត្ដម លោកជំទាវ លោក លោកស្រី ជាទីមេត្រី!*

ក្រោយពីបានធ្វើការពិភាក្សា និងផ្លាស់ប្ដូរយោបល់គ្នាយ៉ាងផុលផុសរួចមក ខ្ញុំបាទមានកិត្តិយសដ៏ខ្ពង់ខ្ពស់សូមគោរពរាយការណ៍នូវលទ្ធផលអង្គសន្និបាត ដូចតទៅះ

១. អង្គសន្និបាតបានឯកភាពលើរបាយការណ៍បូកសរុបសភាពការណ៍អនុវត្តការងារទេសចរណ៍ឆ្នាំ**២០១២-២០១៣ និង**ទិសដៅអនុវត្តបន្ត **"ទេសចរណ៍កម្ពុជាឆ្ពោះទៅរកសមាហរណកម្មអាស៊ានឆ្នាំ២០១៥"** និងការរីករាយចំពោះការរីកចំរើន**ប្រកបដោយមោទនះភាព**លើផ្នែកហេដ្ឋារចនាសម្ព័ន្ធជាច្រើន ដើម្បីបំរើនិងគាំទ្រដល់ការអភិវឌ្ឍវិស័យទេសចរណ៍ មានជាអាទិ៍អាកាសយានដ្ឋាន កំពង់ផែ ស្ពាន ផ្លូវថ្នល់ អគ្គិសនី ទឹកស្អាត និងផ្លូវទៅកាន់តំបន់គោលដៅទេសចរណ៍នានា ដែលការរីកចំរើនផ្នែកហេដ្ឋារចនាសម្ព័ន្ធរូបវន្តទាំងនេះ ពិតជាបានផ្ដល់ឱកាសដល់ប្រជាពលរដ្ឋ ទេសចរក្នុងស្រុក និងទេសចរអន្តរជាតិ អាចធ្វើដំណើរនៅពាសពេញផ្ទៃប្រទេស។

**២.** អង្គសន្និបាតបានកត់សំគាល់ប្រកបដោយសេចក្ដីរីករាយ ដោយនៅ**ឆ្នាំ២០១៣** កម្ពុជាសម្រេចបានកំណើនទេសចរណ៍ **១៧,៥%**ជាមួយនឹងចំនួនទេសចរអន្តរជាតិប្រមាណជាង **៤,២ លាននាក់**។ អង្គសន្និបាតបានឯកភាព និងគាំទ្រនូវចក្ខុវិស័យប្រកបដោយសុទិដ្ឋិនិយម គឺកម្ពុជានឹងទទួលបានទេសចរអន្តរជាតិ **៥លាននាក់** នៅឆ្នាំ**២០១៥** និង **៧,៥ - ៨លាននាក់** នៅឆ្នាំ**២០២០**។ ចក្ខុវិស័យប្រកបដោយសុទិដ្ឋិនិយមនេះ និងបានរួមចំណែកជាវិជ្ជមានដល់ការធ្វើ**សមាហរ- ណកម្មកម្ពុជាក្នុងតំបន់អាស៊ាន**ផងដែរ។ នៅឆ្នាំ២០១៣ អាស៊ានទទួលបានទេសចរ **៩០,២លាននាក់** និងមានផែនការទទួលទេសចរប្រមាណ **១០៧លាននាក់** នៅឆ្នាំ២០១៥។

ឈរលើទស្សនះទាន **"វិស័យទេសចរណ៍បំរើឱ្យសមាហរណកម្មតំបន់ សមាហរណកម្មតំបន់បំរើឱ្យវិស័យទេសចរណ៍"** អង្គសន្និបាតបានទទួលស្គាល់កាល្អានុវត្តភាពថ្មីៗ ដែលកម្ពុជាអាចចាប់យកក្នុងបរិបទនៃការធ្វើសមាហរណកម្មអាស៊ាន និងបានឆ្លុះបញ្ចាំងអំពីបញ្ហាប្រឈមនានា ដែលវិស័យទេសចរណ៍កម្ពុជាកំពុងជួបប្រទះ រួមមានការតភ្ជាប់ (Connectivity) ការសម្រួលការធ្វើដំណើរ និងដឹកជញ្ជូនទេសចរណ៍ ការពង្រឹងក្របខ័ណ្ឌច្បាប់ និងយន្តការស្ថាប័ន ការគ្រប់គ្រង ការធានាគុណភាពផលិតផលទេសចរណ៍ ការអភិវឌ្ឍធនធានមនុស្ស ពិសេសជំនាញវិជ្ជាជីវៈទេសចរណ៍ជាដើម។ ករណីនេះ អង្គសន្និបាតបានលើកឡើងអំពីភាពចាំបាច់នៃការបង្កើនឧត្តមភាពប្រៀបធៀប និង

ភាពប្រកួតប្រជែង (Competitiveness) នៃវិស័យទេសចរណ៍កម្ពុជា ដោយបានលើកឡើងនូវគំនិតមួយចំនួន សំដៅបង្កើនភាពទាក់ទាញនិងការផ្តល់បដិសណ្ឋារកិច្ច និងប្រព័ន្ធសុវត្ថិភាពល្អក្នុងការទស្សនាកម្ពុជា ស្របតាមចក្ខុវិស័យ **អាស៊ានជាគោលដៅទេសចរណ៍កំរិតអន្តរជាតិ និងផ្តល់ភាពកក់ក្តៅដល់ទេសចរ** (ASEAN World Class Destination , ASEAN feel the warmth)។ ទន្ទឹមនឹងនេះ អង្គសន្និបាតបានគាំទ្រទស្សនៈទាន និងយុទ្ធសាស្ត្រអភិវឌ្ឍកម្ពុជា **"កម្ពុជាស្អាត កម្ពុជាបៃតង" ជាគោលដៅទេសចរណ៍ប្រកបដោយភាពទាក់ទាញ និងផ្តល់ភាពកក់ក្តៅដល់ភ្ញៀវទេសចរ"** និងប្តេជ្ញារួមគ្នាបន្តចូលរួមអនុវត្តប្រកបដោយស្មារតីទទួលខុសត្រូវ ដើម្បីធ្វើឱ្យ**ទីក្រុងកាន់តែស្អាត រមណីយដ្ឋានទេសចរណ៍កាន់តែស្អាត មានរបៀបរៀបរយ សណ្តាប់ធ្នាប់ អនាម័យល្អ និងផ្តល់សេវា ប្រកបដោយគុណភាពជាទីពេញចិត្តដល់ភ្ញៀវទេសចរ។**

**៣. អំពីការអភិវឌ្ឍផលិតផលទេសចរណ៍៖**

- អង្គសន្និបាតសូមគាំទ្រ និងកោតសរសើរចំពោះរាជរដ្ឋាភិបាលកម្ពុជា ដែលបានយកចិត្តទុកដាក់រៀបចំផែនការគ្រប់គ្រង និងអភិវឌ្ឍប្រកបដោយនិរន្តរភាពនៅតំបន់ប្រាសាទអង្គរ ដើម្បីឆ្លើយតបនឹងកំណើនទេសចរណ៍យ៉ាងគំហុក នាពេលបច្ចុប្បន្ន និងទៅអនាគត ដែលនេះជាការទទួលខុសត្រូវខ្ពស់របស់រាជរដ្ឋាភិបាល ក្រោមការដឹកនាំដ៏ត្រឹមត្រូវរបស់ ***សម្តេចតេជោនាយករដ្ឋមន្ត្រី*** ក្នុងការការពារ អភិរក្ស និងអភិវឌ្ឍបេតិកភណ្ឌអង្គរ។ អង្គសន្និបាតបានគាំទ្រលើយុទ្ធសាស្ត្រពិពិធកម្មទេសចរណ៍ពីតំបន់ទេសចរណ៍វប្បធម៌-ប្រវត្តិសាស្ត្រអង្គរទៅកាន់តំបន់ឆ្នេរសមុទ្រនិងតំបន់អេកូទេសចរណ៍។ អង្គសន្និបាតគាំទ្រ**យុទ្ធនាការសំអាតឆ្នេរសមុទ្រកម្ពុជា** ក្រោមប្រធានបទ **"ស្រលាញ់ផ្ទៃសមុទ្រខៀវស្រងាត់ ថែរក្សាឆ្នេរខ្សាច់"** ដើម្បីបង្កើនភាពទាក់ទាញទេសចរណ៍មកកាន់តំបន់ឆ្នេរឲ្យបានកាន់តែច្រើនឡើង ព្រោះយើងសង្កេតឃើញថា នៅឆ្នាំ២០១៣ នេះ ភ្ញៀវទេសចរអន្តរជាតិ មកទស្សនាតំបន់ឆ្នេរសមុទ្រ មានចំនួន**៤៩៦.៨៨០នាក់** កើនឡើង**៧៧%** ហើយសង្ឃឹមថានឹងកាន់តែមានការកើនឡើងថែមទៀត ដែលអង្គសន្និបាតស្នើឲ្យក្រុមហ៊ុនអាកាសចរណ៍កម្ពុជាអង្គរអែរ បង្កើនជើងហោះហើរ**សៀមរាប-ក្រុងព្រះសីហនុ**កាន់តែច្រើនថែមទៀត។ អង្គសន្និបាតរីករាយចំពោះការរីកចំរើននៃសភាពការណ៍ទេសចរណ៍នៅកោះរ៉ុង និងកោះរ៉ុងសន្លឹម ដែលបច្ចុប្បន្នមានទេសចរអន្តរជាតិមិនតិចជាង **៤០០នាក់ ក្នុង ១ថ្ងៃ** ទៅទស្សនាតំបន់នេះ។ អង្គសន្និបាតសូមឱ្យអាជ្ញាធរខេត្តព្រះសីហនុ និងសមត្ថកិច្ចពាក់ព័ន្ធ ចាប់អារម្មណ៍ និងយកចិត្តទុកដាក់លើបញ្ហា**អនាម័យ ការគ្រប់គ្រងសំណល់រឹងនិងរាវ ការងារសន្តិសុខនិងសុវត្ថិភាពឱ្យបានល្អ**។

- អង្គសន្និបាតមានការកត់សំគាល់ប្រកបដោយក្តីរីករាយអំពីរីកចំរើនជាបន្តបន្ទាប់នៃវិស័យអេកូទេសចរណ៍និងសហគមន៍ទេសចរណ៍ដែលមកទល់ពេលនេះ មានសហគមន៍ទេសចរណ៍**ចំនួន ៥០** ត្រូវបានបង្កើតឡើង និងកំពុងមានការរីកចំរើនជាលំដាប់។ អង្គសន្និបាតបានគាំទ្រលើការសហការរវាងក្រសួងទេសចរណ៍ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងបរិស្ថានលើការអភិវឌ្ឍលើវិស័យទេសចរណ៍សហគមន៍ រួមមានសហគមន៍អេកូទេសចរណ៍ នៅតាមតំបន់អភិរក្ស និងតំបន់ការពារ **និងកសិទេសចរណ៍** ដែលនេះបង្ហាញពីស្មារតីនៃការរួមគ្នាសហការរវាងក្រសួងទេសចរណ៍ និងក្រសួង-ស្ថាប័នពាក់ព័ន្ធនានា។ **អង្គសន្និបាត**អបអរសាទរចំពោះសមិទ្ធិផលនៃការអភិវឌ្ឍសហគមន៍ទេសចរណ៍នៅតំបន់ទាំងនោះ ដែលបានធ្វើឱ្យប្រជាជនភាគច្រើនបានផ្លាស់ប្តូរមុខរបរពីការបរបាញ់សត្វការកាប់ព្រៃឈើ មក**បង្កបង្កើនផលកសិកម្ម** និង**ផ្តល់សេវាកម្មទេសចរណ៍នៅតាមសហគមន៍** និង**រមណីយដ្ឋានទេសចរណ៍នានា**។ ដើម្បីធ្វើការដឹកនាំផែនការអភិវឌ្ឍសហគមន៍ទេសចរណ៍និងសហគមន៍អេកូទេសចរណ៍ និង**កសិទេសចរណ៍** ឱ្យទទួលបានជោគជ័យ **អង្គសន្និបាត**គាំទ្រលើការ**រៀបចំបង្កើតក្រុមការងារអន្តរក្រសួងមួយ រវាងក្រសួងទេសចរណ៍ ក្រសួងបរិស្ថាន និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**។

អង្គសន្និបាត សូមអបអរសាទចំពោះ**ការរៀបចំពិពណ៌ទេសចរណ៍អាស៊ីប៉ាស៊ីហ្វិក** PATA Travel Mart ការរៀបចំ**សន្និសីទអន្តរជាតិស្តីពីទេសចរណ៍សហគមន៍** និងការរៀបចំ**វេទិកាវិនិយោគទេសចរណ៍អាស៊ាន** (ASEAN Tourism Investment Forum) នៅភ្នំពេញ នាខែកញ្ញា ឆ្នាំ២០១៤ នេះ។

អង្គសន្និបាត អបអរសាទចំពោះរាជរដ្ឋាភិបាល ដែលបានអនុញ្ញាតិឲ្យក្រសួងទេសចរណ៍ ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ សហការជាមួយអង្គការទេសចរណ៍ពិភពលោក UNWTO និងអង្គការយូណេស្កូ UNESCO រៀបចំសន្និសីទអន្តរជាតិដ៏ធំមួយ ស្តីអំពីទេសចរណ៍ និងវប្បធម៌ ដែលមានថ្នាក់រដ្ឋមន្ត្រីទេសចរណ៍ និងវប្បធម៌ និងផ្នែកឯកជនសំខាន់ៗនៅលើពិភពលោក ចូលរួមប្រមាណ **១០០០នាក់** នៅខេត្តសៀមរាបអង្គរ នាសប្តាហ៍ទី១ ខែកុម្ភៈ ឆ្នាំ២០១៥។

**៤. អំពីគុណភាពផលិតផលទេសចរណ៍៖** អង្គសន្និបាតបានឯកភាពចំពោះការវាយតម្លៃដំណាក់កាលដំបូងនៃចលនាប្រឡងប្រណាំងទីក្រុងស្អាត ដែលក្នុងនោះទីក្រុង**បាត់ដំបង** ជាទីក្រុងដែលបានពិន្ទុឈានមុខគេ បន្ទាប់មកក្រុងសៀមរាប ក្រុងកែប និងក្រុងពោធិសាត់ និងមានការប្រគល់សៀវភៅស្តីពី **"កម្មវិធីការងារសម្រាប់ក្រុង/ខណ្ឌបេក្ខភាពនីមួយៗឆ្ពោះទៅទទួលជ័យលាភីផ្ការំដួល ២ ឬ ៣ទង"** ជូនដល់ក្រុង/ខណ្ឌបេក្ខភាព ដើម្បីបន្តអនុវត្តការងារជាយុទ្ធសាស្រ្តនានាបន្ថែមដើម្បីត្រៀមទទួលជ័យលាភីជាទីក្រុងស្អាតឱ្យបានគ្រប់ៗគ្នា នាឱកាសប្រារព្ធទិវាជាតិទីក្រុងស្អាត នៅថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០១៥ ក្រោមប្រធានបទ "**ការរះឡើងនៃទីក្រុងស្អាត ជោគជ័យនៃវិស័យទេសចរណ៍** - Clean City on the Rise, Success of Tourism" ។

អង្គសន្និបាតរីករាយ និងអបអរសាទរចំពោះ**ការបូកសរុបលើកទី២នៃចលនាប្រឡងប្រណាំង "រមណីយដ្ឋានស្អាត សេវាល្អ"** ដែលមានមូលដ្ឋានអាជីវកម្ម និងសេវាកម្មទេសចរណ៍ចំនួន **៥០៨ មូលដ្ឋាន (ក្នុងនោះទទួលបណ្ណសរសើរ ៤៣៤ និងលិខិតសរសើរ៧៤)** និងរមណីយដ្ឋានទេសចរណ៍ចំនួន**៣៨ មូលដ្ឋាន (ក្នុងនោះទទួលបណ្ណសរសើរ ១១ និងលិខិតសរសើរ២៧)** ដែលបានទទួលបណ្ណសរសើរ និងលិខិតសរសើរពីក្រសួងទេសចរណ៍ កាលពីម្សិលម៉ិញនេះ។ អង្គសន្និបាត ស្នើឲ្យមានរៀបចំរង្វាន់លើកទឹកចិត្តដល់បុគ្គលគំរូដែលមានស្នាដៃល្អរួមចំណែកក្នុងចលនាប្រឡងប្រណាំងទីក្រុងស្អាត។ អង្គសន្និបាត ក៏បានស្តាប់យ៉ាងយកចិត្តទុកដាក់នូវបទពិសោធន៍នៃ**សណ្ឋាគារបៃតង ភោជនីយដ្ឋានបៃតង រមណីយដ្ឋានបៃតង** ដែលកំពុងចាប់យកទស្សនៈទានថ្មីនៃទំនួលខុសត្រូវផ្នែកសង្គម និងបរិស្ថាន (Corporate Social Responsibility-CSR) ក្នុងធុរៈកិច្ចរបស់ខ្លួន។ អង្គសន្និបាតអបអរសាទរចំពោះក្រសួងទេសចរណ៍ក្នុងការរៀបចំឱ្យមានស្តង់ដាគុណភាពនៃសេវាកម្មទេសចរណ៍របស់កម្ពុជា ស្របតាមស្តង់ដាអាស៊ាន ជាអាទិ៍ស្តង់ដាសណ្ឋាគារបៃតងអាស៊ាន (ASEAN Green Hotel Standard) ស្តង់ដាផ្ទះស្នាក់អាស៊ាន (ASEAN Green Home-Stay Standard) ស្តង់ដាទីក្រុងទេសចរណ៍ស្អាតអាស៊ាន (ASEAN Clean Tourist City Standard) ស្តង់ដាស្ប៉ាអាស៊ាន (ASEAN Spa & Wellness Standard) ស្តង់ដាបង្គន់សាធារណៈអាស៊ាន (ASEAN Public Toilets Standard) និងស្តង់ដាទេសចរណ៍សហគមន៍អាស៊ាន (ASEAN Community-based Tourism Standard)។ ក្នុងប្រធានបទនៃការពង្រឹងគុណភាពផលិតផលទេសចរណ៍ អង្គសន្និបាតបានស្នើឲ្យក្រសួងទេសចរណ៍ជំរុញការយកចិត្តទុកដាក់បន្ថែមទៀតលើការងារយេនឌ័រក្នុងឧស្សាហកម្មទេសចរណ៍ ព្រោះមានពលករជានារីប្រមាណ ៦០% កំពុងបំរើការងារក្នុងឧស្សាហកម្មនេះ។

**៥.ការអភិវឌ្ឍធនធានមនុស្សក្នុងវិស័យទេសចរណ៍** អង្គសន្និបាតបានប្រមូលផ្តុំយកចិត្តទុកដាក់ដល់ការអភិវឌ្ឍធនធានមនុស្សក្នុងវិស័យទេសចរណ៍ (ទាំងផ្នែកសាធារណៈ និងឯកជន) ព្រោះថា ក្នុងក្របខណ្ឌនៃការធ្វើសមាហរណកម្មអាស៊ាន **ធនធានមនុស្ស**គឺមិនត្រឹមជាកត្តាកំណត់ក្នុងការគ្រប់គ្រង និងអភិវឌ្ឍប្រកបដោយប្រសិទ្ធិភាព គុណភាព និងនិរន្តរភាព ប៉ុន្តែក៏ជាការចូលរួមអនុវត្ត**កិច្ចព្រមព្រៀងទទួលស្គាល់គ្នាទៅវិញទៅមកនៃអ្នកជំនាញទេសចរណ៍**

(MRA)។ អង្គសន្និបាតបានឯកភាពថា ការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈទេសចរណ៍ ត្រូវការចំណាយខ្ពស់ដែលចាំបាច់ឱ្យមានសាលាជាតិបណ្តុះបណ្តាលវិជ្ជាជីវៈទេសចរណ៍ ដើម្បីបង្កលក្ខណៈឱ្យសិស្សអាចចូលរៀនបាន ក្នុងថ្លៃសិក្សាមួយសមរម្យ។ អង្គសន្និបាតបានវាយតម្លៃខ្ពស់ចំពោះកិច្ចសហការរបស់សាលាបណ្តុះបណ្តាលឯកជន សាលាប៉ុលឌុយប្រ៊ួលអង្គការភាពញញឹមនៃកុមារ (សាលា PSE) វិទ្យាស្ថានជាតិពហុបច្ចេកវិទ្យាកម្ពុជា (NPIC) ដែលជាដៃគូក្នុងការបណ្តុះបណ្តាលមគ្គុទ្ទេសក៍ទេសចរណ៍ ហើយអង្គសន្និបាតមាន**ការរីករាយនិងអបអរសាទរ ចំពោះក្រសួងទេសចរណ៍ដែលបាន និងកំពុងសហការជាមួយទីភ្នាក់ងារអភិវឌ្ឍបារាំង (AFD) និងដៃគូរអភិវឌ្ឍផ្សេងៗទៀត ដើម្បីជំរុញការកសាងសាលាបណ្តុះបណ្តាលវិជ្ជាជីវៈទេសចរណ៍ នៅរាជធានីភ្នំពេញ និងខេត្តព្រះសីហនុ**។ អង្គសន្និបាតបានសំដែងការរីករាយចំពោះ**គណៈកម្មាធិការជាតិអ្នកជំនាញទេសចរណ៍** ដែលបានរៀបចំស្តង់ដាកម្មវិធីសិក្សា និងក្របខណ្ឌគុណវុឌ្ឍិសំរាប់ផ្នែកបដិសណ្ឋារកិច្ច និងគេហកិច្ច ស្របតាមស្មារតីនៃកិច្ចព្រមព្រៀងទទួលស្គាល់គ្នាទៅវិញទៅមកអ្នកជំនាញទេសចរណ៍អាស៊ាន (MRA)។ អង្គសន្និបាតក៏បានឯកភាព និងគាំទ្របង្កើតឱ្យមានបណ្តាញអ្នកស្រាវជ្រាវទេសចរណ៍ (Club-Professor) ដែលរួមមានសាស្ត្រាចារ្យទេសចរណ៍នៃសាកលវិទ្យាល័យនានា និងអ្នកឯកទេសចរណ៍មួយចំនួន ដើម្បីផ្លាស់ប្តូរទស្សនទាន បទពិសោធន៍ និងការយល់ដឹងពីទេសចរណ៍ ឱ្យស្របទៅនឹងផែនការយុទ្ធសាស្ត្រ និងការអភិវឌ្ឍទេសចរណ៍របស់រាជរដ្ឋាភិបាល និងការអភិវឌ្ឍទេសចរណ៍នៅក្នុងតំបន់ និងសកលលោក។

**៦. ការងារសិក្សាទីផ្សារ និងផ្សព្វផ្សាយទេសចរណ៍**៖ អង្គសន្និបាតសូមកោតសរសើរចំពោះការខិតខំប្រឹងប្រែងរបស់ក្រសួងទេសចរណ៍ និងផ្នែកឯកជន ក្នុងការជំរុញសកម្មភាពឃោសនាផ្សព្វផ្សាយទេសចរណ៍ (**កម្ពុជាៈ ព្រះរាជាណាចក្រអច្ឆរិយៈ**) ទាំងក្នុង និងក្រៅប្រទេស។ អង្គសន្និបាតបានវាយតំលៃខ្ពស់ និងអរគុណប្រព័ន្ធផ្សព្វផ្សាយក្នុងស្រុកដែលបានជួយផលិត.កម្មវិធីទេសចរណ៍ និងជួយផ្សព្វផ្សាយស្ប៉តឯកសារនិងបទចំរៀងទេសចរណ៍នានា ឯកសារចលនាប្រឡងប្រណាំង **"ទីក្រុងស្អាត រមណីយដ្ឋានស្អាត សេវាល្អ"** ដោយឥតគិតថ្លៃជាប្រចាំ។ អង្គសន្និបាតស្នើឱ្យផ្នែកឯកជនលើកកម្ពស់ស្មារតីយកចិត្តទុកដាក់ និងទទួលខុសត្រូវចូលរួមក្នុងយុទ្ធនាការផ្សព្វផ្សាយទេសចរណ៍ឱ្យបានកាន់តែខ្លាំងក្លាថែមទៀត។ អង្គសន្និបាតគាំទ្រការជំរុញបង្កើតក្រុមប្រឹក្សាភិបាលសិក្សាទិផ្សារ និងផ្សព្វផ្សាយទេសចរណ៍ និងបានឯកភាពចំពោះយុទ្ធសាស្ត្រទីផ្សារទេសចរណ៍កម្ពុជា (រាប់ទាំងយុទ្ធសាស្ត្រសំរាប់ផ្សព្វផ្សាយ និងជំរុញចលនាទេសចរណ៍ក្នុងស្រុក និងអន្តរជាតិ ពិសេស**ទីផ្សារចិន និងឥណ្ឌា**)។ អង្គសន្និបាតបានឯកភាពគាំទ្រជំរុញចលនាទេសចរណ៍ក្នុងស្រុក ដោយបានស្នើឲ្យមានការផលិតឯកសារផ្សព្វផ្សាយជាភាសាជាតិឱ្យបានច្រើន និងជំរុញការគ្រប់គ្រងមណ្ឌលព័ត៌មានទេសចរណ៍នៅគ្រប់រាជធានី-ខេត្តទាំងអស់ឱ្យបានល្អនិងប្រកបដោយគុណភាព។

**៧.ការជំរុញការតភ្ជាប់ (Connectivity) និង សម្រួលការធ្វើដំណើរដល់ទេសចរណ៍**៖ អង្គសន្និបាតសូមកោតសរសើរចំពោះការខិតខំប្រឹងប្រែងរបស់គណៈកម្មការអន្តរក្រសួង ដើម្បីសម្រួលការធ្វើដំណើរ និងដឹកជញ្ជូនទេសចរណ៍ និងអ្នកដំណើរតាមច្រកទ្វារព្រំដែនអន្តរជាតិប៉ោយប៉ែត និងច្រកទ្វារអន្តរជាតិផ្សេងៗទៀត ដែលបានយកចិត្តទុកដាក់ធ្វើការសម្របសម្រួល និងបង្កលក្ខណៈគ្រប់បែបយ៉ាង ដើម្បីឱ្យការដឹកជញ្ជូន និងការធ្វើដំណើរទេសចរណ៍បានប្រព្រឹត្តទៅដោយងាយស្រួលនៅតាមច្រកទ្វារព្រំដែនអន្តរជាតិទាំងផ្លូវគោក ផ្លូវអាកាស និងផ្លូវទឹក។ ប៉ុន្តែ ក៏សូមស្នើគណៈកម្មការនេះជួយពង្រឹងបន្តទៀតព្រោះពេលខ្លះក៏នៅមានជនឆ្លៀតឱកាសបង្កការលំបាកដល់ទេសចរផងដែរ និងសូមជួយពង្រីកបញ្ជរអន្តោប្រវេសន្តបន្ថែមនៅតាមច្រកទ្វារអន្តរជាតិព្រោះបច្ចុប្បន្នចំនួនភ្ញៀវទេសចរកាន់តែកើនឡើងច្រើន។ អង្គសន្និបាតសូមស្នើឱ្យក្រសួង-ស្ថាប័នពាក់ព័ន្ធ សហការចូលរួមអនុវត្តប្លង់មេសំរាប់ការតភ្ជាប់ក្នុងតំបន់អាស៊ាន (Master Plan for ASEAN Connectivity) ឱ្យមានប្រសិទ្ធភាព ដើម្បីចូលរួមកាត់បន្ថយគំលាតក្នុងអាស៊ាន ព្រមទាំងជំរុញឱ្យមានការតភ្ជាប់តាមផ្លូវអាកាស ផ្លូវគោក និងផ្លូវទឹក នៅក្នុងតំបន់កាន់តែច្រើនថែមទៀត ពិសេសលើកទឹកចិត្តដល់ប្រតិបត្តិករតាម

នាវាទេសចរណ៍សមុទ្រ (Cruise Ship) នាវាទេសចរណ៍ទន្លេ និងតាមការហោះហើរដែលមានថ្លៃទាប (Low Cost Carriers) ព្រមទាំងលើកទឹកចិត្តឱ្យអភិវឌ្ឍន៍កំពង់ផែទេសចរណ៍នៅតំបន់ឆ្នេរ និងកំពង់ផែទេសចរណ៍នៅតាមដងទន្លេមេគង្គ និងទន្លេបាសាក់។

**៨. ការរក្សាសន្តិសុខ សុវត្ថិភាពទេសចរណ៍៖** អង្គសន្និបាតសូមកោតសរសើរដោយគោរពដ៏ខ្ពង់ខ្ពស់ចំពោះ **សម្តេចតេជោនាយករដ្ឋមន្ត្រី** ដែលបានដឹកនាំដោយប្រសិទ្ធភាព ក្នុងការនាំមកនូវសុខសន្តិភាព ស្ថេរភាពនយោបាយ សុន្តិសុខ សុវត្ថិភាព របៀបរៀបរយ និងសណ្តាប់ធ្នាប់សង្គមល្អ ហើយបានធ្វើឱ្យភ្ញៀវទេសចរកក់ក្តៅ និងទុកចិត្តក្នុងការមកទស្សនាកម្ពុជាកាន់តែច្រើន។ អង្គសន្និបាតសូមគាំទ្រនិងកោតសរសើរដល់ក្រសួងមហាផ្ទៃ អគ្គស្នងការដ្ឋាននគរបាលជាតិ ដែលបានអនុញ្ញាតឱ្យមូលដ្ឋានអាជីវកម្មនៅតាមគោលដៅទេសចរណ៍នានា បានចូលរួមក្នុងកិច្ចការពារសន្តិសុខ សុវត្ថិភាពទេសចរណ៍ ដោយបង្កើតឡើងជា**សន្តិសុខឯកជន** ក្រោមបណ្តាញសហការ និងត្រួតពិនិត្យពីនគរបាលទេសចរណ៍។ អង្គសន្និបាតបានស្វាគមន៍ដល់ការរៀបចំបង្កើតប្រព័ន្ធសង្គ្រោះភ្ញៀវទេសចរ (Healthy Tourism) ដើម្បីរួម**ចំណែកធានាសុវត្ថិភាពជូនភ្ញៀវទេសចរ**។

**៩. អំពីអភិបាលកិច្ចល្អ និងការពង្រឹងយន្តការទ្រទ្រង់៖** អង្គសន្និបាតយល់ឃើញថា ដើម្បី**ធានាការអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍវិស័យទេសចរណ៍ឆ្នាំ២០១២-២០២០** និងផែនការយុទ្ធសាស្ត្រទេសចរណ៍អាស៊ាន ATSP-2011-2015 ឱ្យទទួលបានជោគជ័យ លុះត្រាតែមានការយកចិត្តទុកដាក់ថែមទៀតក្នុងការ**ពង្រឹងអភិបាលកិច្ចល្អ**ក្នុងវិស័យទេសចរណ៍ (**Good Governance in Tourism**) ពង្រឹងកិច្ចសហប្រតិបត្តិការអន្តរស្ថាប័ន និងភាពជាដៃគូរវាងរដ្ឋ-ឯកជន និងរៀបចំយន្តការសមស្រប ក្នុងការអភិវឌ្ឍវិស័យទេសចរណ៍។ អង្គសន្និបាត សូមអបអរសាទរចំពោះក្រសួងទេសចរណ៍ដែលបានបង្កើតប្រព័ន្ធចុះបញ្ជីអាជ្ញាបណ្ណទេសចរណ៍តាមប្រព័ន្ធ Online និងកម្មវិធីទេសចរណ៍តាមទូរស័ព្ទចល័ត រួមនឹងផែនការគ្រប់គ្រងបណ្តុះបណ្តាល និងគ្រប់គ្រងមគ្គុទេសក៍ទេសចរណ៍ដោយចុះបញ្ជីតាមប្រព័ន្ធបច្ចេកវិទ្យា ដើម្បីសំរួលឱ្យកាន់តែប្រសើរក្នុងការផ្តល់សេវាសាធារណៈ និងបង្កើនការគ្រប់គ្រងប្រកបដោយតម្លាភាព និងប្រសិទ្ធភាព។ អង្គសន្និបាត គាំទ្រជម្រុញរៀបចំ**ផែនការអភិវឌ្ឍន៍ទេសចរណ៍នៅតាមតំបន់ និងរាជធានី-ខេត្ត** ដោយយកគំរូតាមខេត្តស្ទឹងត្រែង និងខេត្តមួយចំនួនដែលបានធ្វើរួចហើយ។ ទន្ទឹមនឹងនេះ អង្គសន្និបាតបានឯកភាពលើការ**រៀបចំ និងពិនិត្យកែសម្រួល និងពង្រឹងរចនាសម្ព័ន្ធការងារក្រសួងទេសចរណ៍ (ទាំងថ្នាក់កណ្តាល និងថ្នាក់ក្រោមជាតិ) ការងារយេនឌ័រក្នុងឧស្សាហកម្មទេសចរណ៍ ការពង្រឹងសមាគមឧស្សាហកម្មទេសចរណ៍ និងការងារហិរញ្ញវត្ថុទ្រទ្រង់ឱ្យបានសមស្រប** ដើម្បីឱ្យដំណើរការការងារប្រទាក់ក្រឡានិងស៊ីសង្វាក់គ្នាស្របតាម**គោលនយោបាយនៃកំណែទម្រង់ស៊ីជំរៅរបស់រាជរដ្ឋាភិបាលក្នុងអាណត្តិទី៥** នេះ។ អង្គសន្និបាតបានឯកភាពលើចក្ខុវិស័យយូរអង្វែងក្នុងការអភិវឌ្ឍវិស័យទេសចរណ៍កម្ពុជា ដោយឈរលើទស្សនៈទាន "**ជំរុញកំណើន និងធានានិរន្តរភាព**" សំដៅធ្វើឱ្យកម្ពុជាក្លាយជាគោលដៅទេសចរណ៍ប្រកបដោយភាពទាក់ទាញ ផ្តល់ភាពកក់ក្តៅដល់ភ្ញៀវទេសចរ និងប្រកបដោយគុណភាពនិងនិរន្តរភាព។ ករណីនេះ អង្គសន្និបាតសំដែងការរីករាយ និងគាំទ្រ**គំរោងពង្រឹងសមត្ថភាព និងគាំពារយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យទេសចរណ៍**(PRCC)ដែលជាគំរោងដ៏មានសារៈសំខាន់ចូលរួមពង្រឹងអភិបាលកិច្ចក្នុងវិស័យទេសចរណ៍ និងដែលជាការផ្តល់ហិរញ្ញប្បទានរបស់ទីភ្នាក់ងារអភិវឌ្ឍបារាំង (AFD)។

ជារួម អង្គសន្និបាតទាំងមូលសូមសំដែងនូវការកោតសរសើរ និងអរគុណយ៉ាងជ្រាលជ្រៅបំផុតចំពោះ **សម្តេចតេជោនាយករដ្ឋមន្ត្រី** ដែលបានខិតខំប្រឹងប្រែងយកអស់ស្មារតី កំលាំងកាយចិត្ត មិនខ្លាចនឿយហត់ ប្រកបដោយឆន្ទៈនយោបាយមោះមុត ដើម្បីបុព្វហេតុប្រទេសជាតិ និងសុភមង្គលរបស់ប្រជាជន ដោយបាននាំមកនូវការបញ្ចប់សង្គ្រាម ការឯកភាពជាតិ សន្តិភាព ស្ថេរភាពនយោបាយ សន្តិសុខ និងសុវត្ថិភាពជូនប្រទេសជាតិ និងប្រជាជន

ដែលនេះជាមូលដ្ឋានគ្រឹះនៃការអភិវឌ្ឍ។ ព្រមជាមួយនោះ **សម្តេចតេជោនាយករដ្ឋមន្ត្រី** បានដឹកនាំនិងជំរុញឥតឈប់ឈរនូវការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ អាកាសយានដ្ឋាន កំពង់ផែ ប្រព័ន្ធធារាសាស្ត្រ សាលារៀន និងហេដ្ឋារចនាសម្ព័ន្ធផ្លូវនៅជនបទ ដែលធ្វើឱ្យប្រទេសជាតិមានការអភិវឌ្ឍរីកចំរើនលើគ្រប់វិស័យ ក្នុងនោះវិស័យទេសចរណ៍ក៏កំពុងមានការរីកចំរើនលើ**មាគ៌ានៃការអភិវឌ្ឍទេសចរណ៍បៃតង** គួរជាទីមោទនៈ។ អង្គសន្និបាតមានជំនឿជឿជាក់យ៉ាងរឹងមាំនិងកក់ក្តៅបំផុតចំពោះការដឹកនាំដ៏ត្រឹមត្រូវ និងឈ្លាសវៃប្រកបដោយគតិបណ្ឌិតរបស់ **សម្តេចតេជោនាយករដ្ឋមន្ត្រី** លើការដឹកនាំ និងជំរុញការអភិវឌ្ឍវិស័យទេសចរណ៍កម្ពុជា ដែលបានជាប្រយោជន៍សំខាន់ចូលរួមដល់ការអភិវឌ្ឍសេដ្ឋកិច្ច-សង្គម ការបង្កើតការងារ ការកាត់បន្ថយភាពក្រីក្រ និងការចូលរួមចំណែកដល់**ការអភិវឌ្ឍសេដ្ឋកិច្ចបៃតង**នៅកម្ពុជា ដោយឈរលើទស្សនៈទានជំរុញ**កំណើន និងនិរន្តរភាព។**

ឆ្លៀតឱកាសនេះ តាងនាមអង្គសន្និបាតទាំងមូល និងខ្ញុំបាទផ្ទាល់ ខ្ញុំសូមគោរពជូនពរ**សម្តេចតេជោនាយករដ្ឋមន្ត្រី និងលោកជំទាវកិត្តិព្រឹទ្ធបណ្ឌិត** ព្រមទាំងក្រុមគ្រួសារ សូមប្រកបដោយសុខភាពល្អបរិបូរណ៍ ប្រាជ្ញាឈ្លាសវៃ កំលាំងខ្លាំងក្លា ដើម្បីដឹកនាំនិងអភិវឌ្ឍកម្ពុជា ឆ្ពោះទៅកាន់ភាពសំបូររុងរឿង និងសុភមង្គលរបស់ប្រជាពលរដ្ឋ។

*- សម្តេចតេជោនាយករដ្ឋមន្ត្រី ជាទីគោរពដ៏ខ្ពង់ខ្ពស់!*

*- ឯកឧត្តម លោកជំទាវ លោក លោកស្រី ជាទីគោរព និងជាទីមេត្រី!*

ខាងលើនេះ ជាយោបល់លើកឡើងមួយចំនួនរបស់អង្គសន្និបាតដែលខ្ញុំបាទសូមគោរពរាយការណ៍ដោយសង្ខេប គោរពជូន **សម្តេចតេជោនាយករដ្ឋមន្ត្រី** មេត្តាជ្រាបដ៏ខ្ពង់ខ្ពស់។

ដើម្បីបានជាអនុសាសន៍ណែនាំដ៏ខ្ពង់ខ្ពស់ និងជាមូលដ្ឋានត្រីវិស័យក្នុងការបន្តអភិវឌ្ឍវិស័យទេសចរណ៍កម្ពុជាប្រកបដោយប្រសិទ្ធភាព គុណភាព និងនិរន្តរភាព ខ្ញុំបាទក្នុងនាមអង្គសន្និបាតទាំងមូល សូមគោរពអញ្ជើញ **សម្តេចតេជោនាយករដ្ឋមន្ត្រី** មេត្តាមានប្រសាសន៍សំណេះសំណាល និងមេត្តាផ្តល់អនុសាសន៍ណែនាំដ៏ខ្ពង់ខ្ពស់។

***សូមគោរពអញ្ជើញ !***